**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**គណៈកម្មាធិការលទ្ធកម្ម**
លេខ : ១២ អយក.គល.សណ

## សេចក្តីជូនដំណឹងស្តីពីការអញ្ជើញចូលរួមដេញថ្លៃ
## ការសាងសង់ អគារទីចាត់ការ ១ខ្នង រួមបញ្ចូលបង្គន់អនាម័យ១ខ្នង ៥បន្ទប់ និងបំពាក់គ្រឿងសង្ហារឹមគ្រប់ចំនួន នៅសាលាបឋមសិក្សា សិរីមង្គល ភូមិព្រែកជ្រៃ ឃុំកាកោងទី២ ស្រុកមុខកំពូល ខេត្តកណ្តាល ថវិកាជំពូក ២១ (គម្រោងវិនិយោគផ្ទាល់ )ឆ្នាំ២០១៧

ក្រសួងអប់រំ យុវជន និងកីឡា សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឲ្យបានជ្រាបថា ក្រសួងអប់រំ យុវជន និងកីឡា នឹងដាក់ឲ្យដេញថ្លៃជាសាធារណៈ ដើម្បីជ្រើសរើសអ្នកទទួលការ ធ្វើ**ការសាងសង់ អគារទីចាត់ការ ១ខ្នង រួមបញ្ចូលបង្គន់អនាម័យ១ខ្នង ៥បន្ទប់ និងបំពាក់គ្រឿងសង្ហារឹមគ្រប់ចំនួន នៅសាលាបឋមសិក្សា សិរីមង្គល ភូមិព្រែកជ្រៃ ឃុំកាកោងទី២ ស្រុកមុខកំពូល ខេត្តកណ្តាល ថវិកាជំពូក ២១ (គម្រោងវិនិយោគផ្ទាល់ ) ឆ្នាំ២០១៧** ។

កិច្ចលទ្ធកម្មនេះនឹងត្រូវបានធ្វើឡើង តាមរយៈវិធីសាស្ត្រការដេញថ្លៃក្នុងស្រុក ស្ថិតក្រោមច្បាប់ និងស្របតាមបទប្បញ្ញត្តិលទ្ធកម្មសាធារណៈ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន បំពេញដើម្បីចូលរួមដេញថ្លៃ និងមានដាក់លក់នៅអង្គភាពលទ្ធកម្ម នៃក្រសួងអប់រំ យុវជន និងកីឡា ដែលមានអាសយដ្ឋាន អគាររដ្ឋបាលថ្មី (សាលាបឋមសិក្សា ចៅពញាហុក) ផ្លូវលេខ៣៨០ សង្កាត់បឹងកេងកងទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ ទូរស័ព្ទលេខ ៖ ០២៣ ២១០ ៤៦៤, ០២៣ ២២០ ៤១២ ទូរសារ/ទូរស័ព្ទលេខ ៖ ០២៣ ២១៥ ២០២ សារអេឡិចត្រូនិច ៖ procurement@moeys.gov.kh គេហទំព័រ ៖ www.moeys.gov.kh/procurement ចាប់ពីថ្ងៃទី២៨ ខែ ធ្នូ ឆ្នាំ ២០១៧ តទៅរៀងរាល់ម៉ោងធ្វើការ ។

អ្នកដេញថ្លៃត្រូវភ្ជាប់មកជាមួយឯកសារដេញថ្លៃនូវ **លិខិតធានាប្រាក់កក់ធានាការដេញថ្លៃ** ដែលមាន ទឹកប្រាក់ចំនួន **៥ ៤៦០ ០០០រៀល (ប្រាំលាន បួនរយហុកសិបពាន់រៀលគត់)** ចេញដោយអគ្គនាយកដ្ឋានរតនាគារជាតិ រតនាគាររាជធានី ខេត្ត ឬធនាគារពាណិជ្ជដៃគូ (មានទម្រង់ និងខ្លឹមសារដូចក្នុងគំរូភ្ជាប់ជាមួយឯកសារដេញថ្លៃ) ។

កាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃ នៅម៉ោង២ និង៣០នាទីរសៀល ថ្ងៃទី៣០ ខែមករា ឆ្នាំ ២០១៨។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋានខាងលើ វេលាម៉ោង ២ និង ៣០នាទីរសៀល ថ្ងៃទី៣០ ខែ មករា ឆ្នាំ ២០១៨ ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយ ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់ ។

ក្រុមហ៊ុន/សហគ្រាស ដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្មដើម្បីទិញឯកសារដេញថ្លៃ និង សាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ។

ថ្ងៃព្រហស្បតិ៍ ១១កើត ខែបុស្ស ឆ្នាំរកា នព្វស័ក.ពស ២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែ ធ្នូ ឆ្នាំ ២០១៧
**ក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន**

ចម្លងជូន៖
- អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
- អង្គភាពប្រឆាំងអំពើពុករលួយ
- ឯកសារ- កាលប្បវត្តិ